# បន្ទប់ស្ថានការណ៍ ថ្ងៃបោះឆ្នោត ឆ្នាំ២០១៣
# Situation Room on Cambodia Election Day 2013

## សេចក្តីថ្លែងការណ៍រួម
## ស្តីពី
## ការស្តារឡើងវិញពន្លកប្រជាធិបតេយ្យនៅកម្ពុជា

ភ្នំពេញ, ថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៤

បន្ទប់ស្ថានការណ៍នៃសមាគម និងអង្គការសង្គមស៊ីវិលនៅកម្ពុជា សូមថ្កោលទោសចំពោះការប្រើអំពើហិង្សាធ្ងន់ធ្ងរបង្ក្រាបបាតុករជាកម្មករ និង បោសសំអាតក្រុមបាតុកររបស់គណបក្សសង្គ្រោះជាតិនៅទីលានប្រជាធិបតេយ្យ និងទីកន្លែងផ្សេងៗទៀតចាប់ពីថ្ងៃទី០២ ដល់ ០៤ ខែមករា ឆ្នាំ២០១៤។ ការបង្ក្រាប និងបោសសំអាតដោយយោធា កងកម្លាំងប្រដាប់អាវុធ និងជនស៊ីវិលដែលរៀបចំទុកនេះ បណ្តាលឲ្យប្រជាពលរដ្ឋស្លាប់ និងរងរបួស ព្រមទាំងមានការចាប់ខ្លួនប្រជាពលរដ្ឋ និងបណ្តាលឲ្យប្រជាពលរដ្ឋមានការភ័យខ្លាចចំពោះស្ថានភាពក្នុងសង្គមនាពេលបច្ចុប្បន្ន។ នេះជាករណីរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរមួយដែលមិនអាចទទួលយកបាន និងធ្វើឲ្យប៉ះពាល់ជាអវិជ្ជមានដល់ដំណើរការលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។

បន្ទប់ស្ថានការណ៍នៃសមាគម និងអង្គការសង្គមស៊ីវិលនៅកម្ពុជា អំពាវនាវ និងស្នើ៖

- រាជរដ្ឋាភិបាលត្រូវអនុញ្ញាតឲ្យមានការរៀបចំធ្វើបាតុកម្មអហិង្សាឡើងវិញនៅទីលានប្រជាធិបតេយ្យ ដើម្បីស្តារឡើងវិញនូវដំណើរការលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។
- រាជរដ្ឋាភិបាលត្រូវបញ្ឈប់ការបង្ក្រាប និងបោសសំអាត និងមធ្យោបាយហិង្សាផ្សេងៗពីសំណាក់ក្រុមកម្លាំងប្រដាប់អាវុធ លើប្រជាពលរដ្ឋស្លូតត្រង់ជាបន្ទាន់។
- គណបក្សនយោបាយទាំងពីរ ត្រូវចរចាដោយសន្តិវិធី និងយកផលប្រយោជន៍ជាតិ ការគោរពសិទ្ធិមនុស្ស និងដំណើរការប្រជាធិបតេយ្យជាធំ។

**ព័ត៌មានបន្ថែមសូមទាក់ទង៖**

១. លោក នី ចរិយា ប្រធានស៊ើបអង្កេតនៃសមាគម អាដហុក ០១១ ២៧ ៤៩ ៥៩

២. លោកស្រី ធីតា ឃឹះ នាយិកាអង្គការសីលការ ០១២ ៨៣ ៨៤ ៦៤

| | | |
|---|---|---|
| ៣. លោកស្រី រស់ សុភាព | នាយិកាអង្គការGADC | ០១២ ៦២ ៧៨ ៥៧ |
| ៤. លោក សុក សំអឿន | ប្រធានសម្របសម្រួលនៃCHRAC | ០១២ ៩០ ១១ ៩៩ |
| ៥. លោក ម៉ាក ចំរើន | ប្រធានសមាគមយុវជនខ្មែរ | ០១៧ ៧៨ ៨៩ ៥៥ |
| ៦. លោក ហង្ស ពុទ្ធា | នាយកប្រតិបត្តិអង្គការនិកហ្វិច | ០១២ ៩៥ ៩៦ ៦៦ |
| ៧. លោក យ៉េង វីរៈ | នាយកប្រតិបត្តិអង្គការ CLEC | ០១២ ៨០ ១២ ៣៥ |
| ៨. លោក តឹក វណ្ណារ៉ា | នាយកប្រតិបត្តិរងNGO Forum | ០១២ ៧៩ ៣៤ ៨៩ |
| ៩. លោក ប៉ា ងួនទៀង | នាយកប្រតិបត្តិ CCIM | ០៦០ ៤០ ៩៩ ៩៩ |
| ១០. លោក អ៊ូ វីរៈ | ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា | ០១២ ៤០ ៤០ ៥១ |
| ១១. លោក យង់ គិមអេង | ប្រធាន PDP-Center | ០១៦ ៨២ ៨២ ១១ |
| ១២. លោក ព្រាប កុល | នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា | ០១២ ៨៧ ៧៨ ៣៣ |
| ១៣. លោក ជាង សុខា | នាយកប្រតិបត្តិអង្គការ YRDP | ០១២ ៣៦ ០៤ ៦៤ |
| ១៤. លោក សុខ ពិទូរ្យ | នាយកប្រតិបត្តិក្រុមប្រឹក្សាយុវជនកម្ពុជា | ០១៧ ២៧ ៣៣ ០៣ |
| ១៥. លោកស្រី អែល សុធារី | ប្រធានកម្មវិធីនៃអង្គការ CCC | ០៩៧ ៥៤៧ ៨៩ ១០ |
| ១៦. លោក សាម អ៊ីន | នាយកប្រតិបត្តិនៃLWD | ០១២ ៥៥ ១៨ ៨៦ |
| ១៧. លោក ហ៊ឹម យន់ | អ្នកសម្របសម្រួលអង្គការCISA | ០១២ ៩៤ ៧០ ២២ |
| ១៨. លោក គល់ បញ្ញា | នាយកប្រតិបត្តិអង្គការCOMFREL | ០១២ ៩៤ ២០ ១៧ |
| ១៩. លោក ឈួន បូរិត | នាយកប្រតិបត្តិ KYSD | ០១២ ៧៩ ៨៤ ៨៨ |
| ២០. លោក សួន ប៊ុនស័ក្តិ | អគ្គលេខាធិការCHRAC | ០១២ ៣៤ ៤៣ ៥៧ |